# សិទ្ធិទទួលបានការពិនិត្យមើលដោយតុលាការលើការឃាត់ខ្លួន

(*habeas corpus)*

First of all, the plea of *habeas corpus* allowed supervision of the legality of the arrest and initial detention. In addition, detainees had the absolute right, which could be upheld in court, to consult a lawyer forty-eight hours after their arrest. Any supplementary period was subject to court supervision. Finally, detainees had the right to inform a family member or a friend of their detention and to be examined by a doctor (**ECHR, McBride v. the United Kingdom, Judgement of 26 May 1993**, paras. 61-65).

ជាដំបូង ការអះអាងអំពី *habeas corpus* អនុញ្ញាតនូវការត្រួតពិនិត្យលើភាពត្រឹមត្រូវតាមច្បាប់លើការឃាត់និងឃុំខ្លួនជាដំបូង។ បន្ថែមពីលើនេះ អ្នកជាប់ឃុំមានសិទ្ធិដាច់ខាត ដែលអាចទទួលយកក្នុងតុលាការ ក្នុងការពិគ្រោះយោបល់ជាមួយមេធាវីក្នុងអំឡុងពេល៤៨ម៉ោង បន្ទាប់ពីការឃាត់ខ្លួន។ រយៈពេលបន្ថែម ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យដោយតុលាការ។ ជាចុងក្រោយ អ្នកជាប់ឃុំមានសិទ្ធិជូនដំណឹងដល់សមាជិកគ្រួសារឬមិត្តភ័ក្រ អំពីការឃុំខ្លួននិងត្រូវបានពិនិត្យដោយវេជ្ជបណ្ឌិត។

After having specified that the right to habeas corpus is in fact an element of the right of *amparo* (para. 32), the Court declared that *habeas corpus* performs a vital role in ensuring that a detainee's life and physical integrity are respected, in preventing the keeping of his whereabouts secret and in protecting him against torture or other cruel, inhuman, or degrading punishment or treatment (para. 35). It concluded that the right of *habeas corpus* and the right of *amparo* are judicial remedies that are essential for the protection of the rights whose derogation is prohibited by article 27 (2) and that serve, moreover, to preserve legality in a democratic society (para.42). Accordingly, the rights of *hebeas corpus* and *amparo* may not be suspended by States Parties, even during states of emergency ( IACHR, Advisory Opinion OC-8/87 of January 1987 *habbeas corpus* and *amparo* as non-derogable rights).

ក្រោយពីមានការបញ្ជាក់ថាសិទ្ធិ *habeas corpus* ជាធាតុផ្សំនៃសិទ្ធិ *amparo* តុលាការ ប្រកាសថា *habeas corpus* ដើរតួនាទីសំខាន់ក្នុងការធានាថាបូរណភាពរាងកាយនិងជីវិតរបស់អ្នកជាប់ឃុំ ត្រូវបានគោរព ដើម្បីបង្កាការការបាត់ដំណឹងអំពីកន្លែងនៅរបស់គាត់ និងការពារគាត់ប្រឆាំងនឹងអំពើទារុណកម្ម ឬអមនុស្សធម៌ ។ ជាការសន្និដ្ឋានគឺថា *habeas corpus* និង សិទ្ធិ *amparo* ជាដំណោះស្រាយផ្លូវច្បាប់

ដែលចាំបាច់សម្រាប់ការពារសិទ្ធិ ដែលការផ្អាកអនុវត្តសិទ្ធិនេះ ត្រូវបានហាមដោយមាត្រា២៧(២)។ បន្ថែមពីលើនេះ សិទ្ធិនេះដើរតួនាទីការពារភាពស្របច្បាប់ក្នុងសង្គមប្រជាធិបតេយ្យ។ ផ្អែកតាមនេះ សិទ្ធិថា *habeas corpus* និង សិទ្ធិ *amparo* មិនអាចត្រូវបានផ្អាកដោយរដ្ឋភាគី ទោះបីក្នុងអំឡុងពេល មានស្ថានភាពគ្រោះអាសន្ន។

**កំណត់សំគាល់៖** ក. សិទ្ធិមានមេធាវី មានចែងក្នុងមាត្រា១៤នៃកតិកាសញ្ញាស្តីពីសិទ្ធិមនុស្ស ដោយប្រយោល។ ទោះបីជាយ៉ាងនេះក្តី វាមានភាពមិនច្បាស់ថាសិទ្ធិនេះជាសិទ្ធិដាច់ខាតឬយ៉ាងណា? ខ្លឹមសារដកស្រង់ខាងលើ ស្នើថាសិទ្ធិពិគ្រោះជាមួយមេធាវីជាសិទ្ធិដាច់ខាត។ **ខ.** ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧ បានចែងអំពីសិទ្ធិមានមេធាវីក្នុងមាត្រា៩៨។ **គ.** កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ មាត្រា៩ ចែងស្រដៀងខ្លឹមសារ *harbeas corpus* ទោះបីជាមិនអះអាងថា ជាសិទ្ធិដាច់ខាត។ យោបល់ដកស្រង់ខាងលើស្នើថា សិទ្ធិនេះជាសិទ្ធិដាច់ខាតនឹងមិនត្រូវផ្អាកការអនុវត្ត។

## មាត្រា ៩៨ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន

ក្នុងរយៈពេល២៤ ម៉ោងបានកន្លងផុតទៅ តាំងពីពេលផ្តើមនៃការឃាត់ខ្លួនមកនោះ បុគ្គលដែលឃាត់ខ្លួនអាចសុំសន្ទនាជាមួយមេធាវីឬជាមួយជនណាម្នាក់ដែលខ្លួនជ្រើសរើស កុំឱ្យតែជននេះមានការទាក់ទិននៅក្នុងរឿងជាមួយ ។ ជននេះត្រូវបានទទួលដំណឹងពីការស្នើសុំជ្រើសរើសនេះ តាមគ្រប់មធ្យោបាយនិងជាបន្ទាន់ ។ ជននេះអាចចូលទៅកាន់កន្លែងឃាត់ខ្លួននិងទាក់ទងជាមួយបុគ្គលសាមីខ្លួនបាន៣០(សាមសិប) នាទីក្នុងលក្ខខណ្ឌទទួលការសម្ងាត់នៃការសន្ទនានេះ ។ ក្រោយការសន្ទនាជននេះអាចធ្វើកំណត់សម្គាល់ជាលាយលក្ខណ៍អក្សរ ដែលត្រូវភ្ជាប់ជាមួយសំណុំរឿង ។

## មាត្រា៩នៃកតិកាសញ្ញាស្តីពីសិទ្ធិប្រជាពលរដ្ឋ

.................

៤.ជនណាដែលត្រូវដកហូតសេរីភាព ដោយការឃាត់ខ្លួនឬឃុំខ្លួន ត្រូវតែមានសិទ្ធិដាក់ពាក្យបណ្តឹង ដើម្បីឲ្យតុលាកាអាចសម្រេចដោយមិនពន្យារពេល អំពីនីត្យានុកូលភាពនៃការឃុំខ្លួន និងបង្គាប់ឲ្យនៅក្រៅឃុំ បើការឃុំខ្លួននោះមិនស្របច្បាប់។

៥.ជនណាដែលបានរងគ្រោះដោយសារការឃាត់ខ្លួន ឬឃុំខ្លួនខុសច្បាប់ មានសិទ្ធិទាមទារសំណង។